# WHO IS BRAD GORDON?



**ឆ្នាំ ១៩៩១**

ជានិស្សិតក្នុងកម្មសិក្សាផ្លាស់ប្តូរបទពិសោធន៍នៅសកលវិទ្យាល័យ (National University of Singapore)។

**ឆ្នាំ ១៩៩១**

បានបញ្ចប់បរិញ្ញាប័ត្រពីសកលវិទ្យាល័យ Brown University ដោយទទួលបានប័ណ្ណសរសើរកិត្តិយសក្នុងជំនាញអក្សរសាស្ត្រ និងសង្គម។

**ឆ្នាំ ១៩៨៨**

ជាគ្រូបង្រៀនស្ម័គ្រចិត្តដែលធ្វើការជាមួយអង្គការ Save the Children និង UNHCR បង្រៀនកុមារនៅជំរុំជនភៀសខ្លួននៅប្រទេសសិង្ហបុរី និង ប្រទេសថៃ។ នៅប្រទេសថៃ គាត់បានបង្រៀនភាសាអង់គ្លេសដល់កុមារភៀសខ្លួនកម្ពុជា។

**ឆ្នាំ ១៩៨៨**

បានទទួលប័ណ្ណសរសើរកត្តិយសនៃកម្មវិធីអាហារូបករណ៍ C.V. Starr ដែលបានប្រគល់ដោយមហាសង្ឃនាយក Desmond Tutu ក្នុងនាមជាអ្នកធ្វើការជាមួយជនភៀសខ្លួន។



**ឆ្នាំ ១៩៨៩**

ជាគ្រូបង្រៀនដោយស្ម័គ្រចិត្តដល់ព្រះសង្ឃមកពីប្រទេសឡាវ នៅ Providence, Rhode Island។

**ឆ្នាំ ១៩៩៥**

បញ្ចប់ការសិក្សាពីមហាវិទ្យាល័យច្បាប់ Harvard Law School ដែលស្ថិតនៅក្នុងចំណោមមហាវិទ្យាល័យច្បាប់ដ៏ល្បីទូទាំងពិភពលោក។

**ឆ្នាំ ១៩៩៥**

ចាប់ផ្តើមប្រកបវិជ្ជាជីវៈផ្នែកច្បាប់នៅទីក្រុងញូយក បន្ទាប់មកនៅទីក្រុងឡុងដ៍ សិង្ហបុរី ទីក្រុងហុងកុង និងទីក្រុងតូក្យូ បានធ្វើការជាមួយការិយាល័យមេធាវីអន្តរជាតិល្បីៗជាច្រើន។



**អង្គហេតុ**

ចំណង់ចំណូលចិត្តមួយរបស់ លោក Brad គឺការអភិរក្ស និងលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្របុរាណរបស់ប្រទេសកម្ពុជា។

**ឆ្នាំ ២០០៧**

បានធ្វើការផ្លាស់ប្តូរទីស្នាក់នៅមកប្រទេសកម្ពុជា និងនាំអ្នកវិនិយោគបន្ថែមមកក្នុងប្រទេស។

**ឆ្នាំ ២០០៩ - ឆ្នាំ ២០២១**

បានផ្តល់ប្រឹក្សាយោបល់ដល់គ្រួសារដែលជាម្ចាស់ជំនួញធំៗជាច្រើន អង្គការក្រៅរដ្ឋាភិបាល និងសហគ្រិនជាច្រើនផ្សេងទៀត។ លោកក៏បានផ្តល់ប្រឹក្សាយោបល់ដល់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។

**បច្ចុប្បន្ន**

ចាប់តាំងពីឆ្នាំ ២០១៨ មក លោក Brad បានដឹកនាំក្រុមស៊ើបអង្កេតលើ លោក សុធា អរុណ ដែលជាអតីតនាយកប្រតិបត្តិនៃអង្គការអន្តរជាតិ សុវណ្ណកុមារ និងបក្ខពួករបស់លោក សុធា អរុណ។ លោកសុធា អរុណ និងបក្ខពួកត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម អំពើហិង្សាដោយចេតនាលើកុមារ ការរំលោភបំពាន ការឆបោក និងបទល្មើសដទៃទៀត។ ជាលទ្ធផល លោក Brad ត្រូវបានទទួលរងនូវការគំរាមកំហែងដល់អាយុជីវិត និងត្រូវបានលោក សុធា អរុណ ប្តឹងពីបទប្លន់ប្រដាប់អាវុធ (ដែលពាក្យបណ្តឹងនោះត្រូវបានតុលាការទម្លាក់ចោល) ហើយខ្លួនលោកផ្ទាល់ និងក្រុមការងាររបស់លោកប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ។

**អង្គហេតុ**

លោកបានធ្វើការអស់រយៈពេលប្រមាណ៩ឆ្នាំ ក្នុងការនាំសម្បត្តិវប្បធម៌ខ្មែរមកកាន់ប្រទេសកម្ពុជាវិញដោយសុវត្ថិភាព។



**ឆ្នាំ ២០០៩ - ឆ្នាំ ២០២១**

Brad មានចំណាប់អារម្មណ៍មកលើប្រទេសកម្ពុជាជាខ្លាំង ដែលធ្វើអោយលោកបានសម្រេចចិត្តបង្កើតក្រុមហ៊ុនប្រឹក្សាយោបល់មួយនៅប្រទេសកម្ពុជាដែលនៅបន្តប្រតិបត្តិការរហូតមកដល់បច្ចុប្បន្ន។

**ឆ្នាំ ២០០៩ - ឆ្នាំ ២០២១**

ការងារផ្សេងៗទៀត រួមទាំងការផ្តល់ប្រឹក្សាដល់ក្រុមហ៊ុនផលិតភាពយន្តអន្តរជាតិដែលបានផលិតភាពយន្តនៅប្រទេសកម្ពុជា ដែលរួមមាន “មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ” និងរឿង “Buoyancy” ។

